United Nations
Educational, Scientific and
Cultural Organization

Organisation
des Nations Unies
pour l'éducation,
la science et la culture

UNITED NATIONS
HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER
Cambodia

# សេចក្តីប្រកាសព័ត៌មានបន្ទាន់

**ការប្រារព្ធទិវាសេរីភាពសារព័ត៌មានពិភពលោក**

***សុវត្ថិភាពរបស់អ្នកសារព័ត៌មានក្នុងប្រទេសកម្ពុជា ៖***

***នីតិរដ្ឋក្នុងការធានាសុវត្ថិភាពរបស់អ្នកសារព័ត៌មាន និង ប្រយុទ្ធប្រឆាំងនិទណ្ឌភាព***

**៣ ឧសភា ២០១៤**

**សណ្ឋាគារ Intercontinental**

**៨.០០-១២.០០**

ថ្ងៃទី៣ខែឧសភាត្រូវបានប្រកាសជាទិវាសេរីភាពសារព័ត៌មាន នៅមហាសន្និបាតរបស់អង្គការសហប្រជាជាតិនៅឆ្នាំ១៩៩៣ បន្ទាប់ពីអនុសាសន៍ត្រូវបានអនុម័តឡើងនៅក្នុងសន្និសីទទូទៅរបស់អង្គការយូណេស្កូលើកទី២៦ នៅឆ្នាំ១៩៩១។ វាជាថ្ងៃមួយដើម្បីលើកទឹកចិត្តនិងបង្កើតគំនិតផ្តួចផ្តើម ដើម្បីគាំទ្រសេរីភាពសារព័ត៌មាន វាយតម្លៃពីស្ថានភាពនៃសេរីភាពសារព័ត៌មានទូទាំងសកលលោក និងក៏ជាថ្ងៃរំលឹកដល់រដ្ឋាភិបាលពីតម្រូវការគោរពដល់ការតាំងចិត្តរបស់ពួកគេចំពោះសេរីភាពក្នុងការបញ្ចេញមតិ។

ប្រធានបទនៃទិវាសេរីភាពសារព័ត៌មានពិភពលោកឆ្នាំ២០១៤ គឺ *សុវត្ថិភាពរបស់អ្នកសារព័ត៌មានក្នុងប្រទេសកម្ពុជា៖នីតិរដ្ឋក្នុងការធានាសុវត្ថិភាពរបស់អ្នកសារព័ត៌មាន និង ប្រយុទ្ធប្រឆាំងនិទណ្ឌភាព* ។ ការប្រារព្ធពិធីអបអរទិវាសេរីភាពសារព័ត៌មានពិភពលោកឆ្នាំនេះមានគោលបំណងផ្តល់ជាវេទិកាសន្ទនាមួយដល់អ្នកតំណាងប្រព័ន្ធផ្សព្វផ្សាយ អ្នកប្រកបរបបសារព័ត៌មាន និងអង្គការសង្គមស៊ីវិលដើម្បីជជែកវែកញែកអំពីការប្រឈមនិងបញ្ហាបច្ចុប្បន្ននានាជុំវិញសុវត្ថិភាពរបស់អ្នកសារព័ត៌មាននៅកម្ពុជា។

នៅឆ្នាំនេះ អង្គការសហប្រជាជាតិបង្ហាញពី *ផែនការសកម្មភាពរបស់អង្គការសហប្រជាជាតិស្តីពីសុវត្ថិភាពរបស់អ្នកសារព័ត៌មាន និង បញ្ហានិទណ្ឌភាព។* ផែនការសកម្មភាពនេះមានគោលបំណងបង្កើតបរិយាកាសសេរី និង សុវត្ថិភាពសម្រាប់អ្នកសារព័ត៌មាន និង បុគ្គលិកប្រព័ន្ធផ្សព្វផ្សាយ ដើម្បីពង្រឹងសន្តិភាព លទ្ធិប្រជាធិបតេយ្យ និង ការអភិវឌ្ឍ។ ផែនការនេះមានគោលបំណងបង្កើតនូវយន្តការសម្របសម្រួលជាមួយ

រដ្ឋាភិបាល អង្គការសង្គមស៊ីវិល និង ស្ថាប័នប្រព័ន្ធផ្សព្វផ្សាយ ដើម្បីដោះស្រាយបញ្ហាទាក់ទងនឹងសុវត្ថិភាពរបស់អ្នកសារព័ត៌មាន ក៏ដូចជាជួយបង្កើតច្បាប់ និង យន្តការ ដែលមានលក្ខណៈល្អចំពោះសេរីភាពខាងបញ្ចេញមតិ និង ព័ត៌មាន ក្រោមគោលការណ៍ និង វិធានអន្តរជាតិដែលមានស្រាប់។

អគ្គលេខាធិការ បាន គីមូន និយាយនៅទីស្នាក់ការសហប្រជាជាតិ ស្តីពី“ សេរីភាពខាងប្រព័ន្ធផ្សព្វផ្សាយសម្រាប់អនាគតល្អៈ កំណត់ពីរបៀបវារៈអភិវឌ្ឍក្រោយឆ្នាំ ២០១៥” ថា “ *សេរីភាពខាងបញ្ចេញមតិ* ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និង សិទ្ធិជាសកលក្នុងការទទួលបានចំណេះដឹង នឹងពង្រឹងកិច្ចខិតខំប្រឹងប្រែង ដើម្បីសម្រេចនូវលទ្ធផលចុងក្រោយសម្រាប់មនុស្ស និង ផ្កាយព្រះគ្រោះ” < “http://www.un. org/sg/statements/index.asp?nid=” > ។

ការពិភាក្សាបង្ហាញពីប្រធានបទនៃទិវាសេរីភាពសារព័ត៌មានពិភពលោកឆ្នាំនេះ ដោយមានការបង្ហាញពីឱកាសប្រារព្ធគោលការណ៍ជាមូលដ្ឋាននៃសេរីភាពនេះ និង គោរពដល់អ្នកសារព័ត៌ ដែលបានបាត់បង់ជីវិតក្នុងពេលបំពេញភារកិច្ច នឹងបង្ហាញពីសារៈសំខាន់ក្នុងការអភិវឌ្ឍរបស់ប្រព័ន្ធផ្សព្វផ្សាយ សុវត្ថិភាពរបស់អ្នកសារព័ត៌មាន និង នីតិរដ្ឋ ព្រមទាំងនិរន្តរភាព និង សុចរិតភាពនៃសារព័ត៌មាន។

ទិវាសេរីភាពសារព័ត៌មានពិភពលោកឆ្នាំ ២០១៤ នឹងត្រូវប្រារព្ធដោយការិយាល័យរបស់អង្គការយូណេស្កូ នៅភ្នំពេញ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) រួមសហការជាមួយវិទ្យាស្ថានសារគមនាគមន៍កម្ពុជា (CCI) ក្លឹបអ្នកកាសែតកម្ពុជា (CCJ) មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) សមាគមកម្ពុជាការពារអ្នកកាសែត (CAPJ) និងដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយនិងគមនាគមន៍ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

ចប់

## សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកកាន់:

កញ្ញា Jamie Lee (UNESCO) តាមរយៈលេខទូរស័ព្ទ 078 77 21 44 ឬ hj.lee@unesco.org

កញ្ញា Bushra rahman (OHCHR) តាមរយៈលេខទូរស័ព្ទ 012 79 01 78ឬ brahman@ohchr.org